ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

កំណត់ហេតុកិច្ចប្រជុំថ្នាក់ដឹកនាំ
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែមីនា ឆ្នាំ២០២៣

១. សេចក្តីផ្តើម

នៅថ្ងៃអង្គារ ១៤កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមីនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ម៉ូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តម លោកជំទាវអនុប្រធាន ឯកឧត្តមទីប្រឹក្សា នាយកខុទ្ទកាល័យ ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានទាំងបួន។

កិច្ចប្រជុំដំណើរការតាមរបៀបវារៈដូចខាងក្រោម ៖

១) មតិស្វាគមន៍ និងបើកកម្មវិធីរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
២) បទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
៣) បទបង្ហាញរបស់**ឯកឧត្តមវេជ្ជ. រស់ សីលវ៉ាត់** ស្តីពីការអភិវឌ្ឍយន្តការ ដើម្បីពង្រីកការគ្របដណ្តប់នៃការការពារសង្គមដល់កម្មករកំសាន្តទេសចរណ៍។
៤) ការផ្តល់អនុសាសន៍បូកសរុបលទ្ធផល និងបិទកម្មវិធីដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. ដំណើរការ និងមតិពិភាក្សានៃកិច្ចប្រជុំ

១) មតិស្វាគមន៍ និងបើកកិច្ចប្រជុំរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី បានបើកកិច្ចប្រជុំ និងមានមតិស្វាគមន៍ដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំប្រចាំខែ ដោយផ្ទាល់ និងតាមប្រព័ន្ធនិមិត្ត ដែលជាឱកាសមួយក្នុងការពិនិត្យលើការងាររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា ការបើកកិច្ចប្រជុំ ការជួបជុំគ្នា ដើម្បីពិនិត្យអំពីវឌ្ឍនភាពការងារក្នុងខែកន្លងទៅ និងផែនការសកម្មភាពការងារដែលត្រូវធ្វើនាខែបន្ទាប់។

កិច្ចប្រជុំដំណើរការតាមរបៀបវារៈដូចខាងក្រោម ៖

១. របាយការណ៍ដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២. អនុសាសន៍បូកសរុប និងកិច្ចពិភាក្សារបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២) របាយការណ៍សកម្មភាពដោយ ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សេចក្តីរាយការណ៍ពីសកម្មភាព លទ្ធផលនានារបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមិនា ឆ្នាំ២០២៣។

នៅក្នុងបទបង្ហាញបានរាយការណ៍ការងាររបស់ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន និងរាយការណ៍វឌ្ឍនភាពឆ្លើយតបនៃអនុសាសន៍នាខែកន្លងមក ។ សកម្មភាព និងព្រឹត្តិការណ៍សំខាន់ៗរួមមាន ៖

- បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំពិភាក្សាជាមួយគណៈប្រតិភូ GFATM។
- បានអញ្ជើញជាអធិបតីភាពក្នុងពិធីសិក្ខាសាលា ស្តីពីវឌ្ឍនភាពនៃការអនុវត្ត FTCI នៅខេត្តសៀមរាប។
- បានដឹកនាំកិច្ចប្រជុំប្រចាំខែ ខែមីនា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាព**សម្តេចតេជោ ហ៊ុន សែន**។
- ជាកិត្តិយសបានអញ្ជើញចូលរួមក្នុងកម្មវិធី Kalyan ជាកម្មវិធីមួយនៅទូរទស្សន៍ CNC លើប្រធានបទ "**កម្ពុជាឆ្ពោះទៅរកការបញ្ចប់ជំងឺអេដស៍កាលពី ឆ្នាំ២០២៥**"។
- អនុញ្ញាតឱ្យមានដំណើរទស្សនកិច្ចដោយអនុបណ្ឌិតសភា សម្រាប់លោក Yukihisa Fujita អតីតឧបនាយករដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុន។
- បានពិនិត្យ និងមានមតិយោបល់គ្រប់ឯកសារទាំងអស់ជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

- បានពិនិត្យ និងចុះហត្ថលេខាលើឯកសារបេសកកម្ម និងរបាយការណ៍ទាំងអស់។
- បានចូលរួមជាតំណាងប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងកិច្ចប្រជុំលើកទី៤២ ស្តីពីវឌ្ឍនភាពសុខភាពរបស់ក្រសួងសុខាភិបាល។
- បានចូលរួមក្នុងទិវាស្ត្រីជាតិ នៅស្រុកបសេដ្ឋ។
- បានចូលរួមក្នុងកិច្ចប្រជុំ ស្តីពី OPTIMA 2023 តាមប្រព័ន្ធអនឡាញ។
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើកញ្ចប់សកម្មភាពសំខាន់ៗ ដើម្បីកាត់បន្ថយការរើសអើងក្នុងចំណោម PLWHIV និងក្រុមគោលដៅ។
- បានចូលរួមក្នុងការពិនិត្យលើសំណើមូលនិធិអូស្ត្រាលីតាមរយៈ UNAIDS។
- បានដឹកនាំក្រុមបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីធ្វើសេចក្តីព្រាងគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍នៅត្រឹមឆ្នាំ២០២៥។
- បានដឹកនាំក្រុមស្នូលរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីពិនិត្យលើសេចក្តីព្រាងគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍ ឆ្នាំ២០២៥។
- បានចូលរួមជាវាគ្មិន ដើម្បីចែកចាយចំណេះដឹងមេរោគហ៊ីវ និងជំងឺអេដស៍ ដែលបានធ្វើឱ្យទាន់សម័យដែលរៀបចំឡើងដោយ MoEYS នៅខេត្តកំពង់ឆ្នាំង។
- បានចូលរួមជាគ្រូបង្វឹក ស្តីពី "ការបណ្តុះបណ្តាលរបាយការណ៍វឌ្ឍនភាពដែលរៀបចំឡើងដោយ MoWAs" នៅខេត្តសៀមរាប។
- បានចូលរួមជាគ្រូបង្វឹក ស្តីពី "ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដែលរៀបចំឡើងដោយ MoEYS និង ATF" នៅខេត្តកំពង់ចាម។
- បានចូលរួមទិវាអន្តរជាតិ ដើម្បីបញ្ចប់ជំងឺមហារីកឆ្នាំ២០២៥ ដែលរៀបចំឡើងដោយ MoH។

៣) បទបង្ហាញរបស់**ឯកឧត្តមវេជ្ជ. រស់ សីលវ៉ាត់ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

ឯកឧត្តមវេជ្ជ. **រស់ សីលវ៉ាត់** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើបទបង្ហាញ ស្តីពីការអភិវឌ្ឍយន្តការ ដើម្បីពង្រីកការគ្របដណ្តប់នៃការការពារសង្គមដល់កម្មករកំសាន្តទេសចរណ៍។

- បានយល់ព្រមការស្នើសុំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចុះឈ្មោះរបស់នារីកម្សាន្តសប្បាយ និងTG តាមនិយមន័យរបស់ក្រសួងទេសចរណ៍។
- EW និងTG អាចចុះឈ្មោះនៅកន្លែងធ្វើការផ្ទាល់តែម្តង ដោយបណ្ណសមធម៌មិនបានបញ្ជាក់ពីស្ថានភាពការងាររបស់ពួកគាត់ទេ។
- ក្រសួងផែនការត្រៀមចេញនូវគតិយុត្តគឺ អ្នកក្របំផុតបានបណ្ណ ID Poor និងអ្នកក្រមធ្យមបានបណ្ណ បសស ពណ៌លឿង។

- ឯកឧត្តម ជា ប៉ោ បានទាក់ទងជាមួយ MoI និងបានទទួលការអធិប្បាយ ដើម្បីមានលិខិតមួយច្បាប់ពីលេខាធិការឯកឧត្តមនៃ MoI ដែលទទួលខុសត្រូវចំពោះប្រព័ន្ធផ្សព្វផ្សាយដែលអាចជួយសម្រួលដល់ការធ្វើការទាក់ទងនឹងវិទ្យុ ABC។
- ឯកឧត្តមវេជ្ជ. ស៊ឹម គឹមសែន បានស្នើឱ្យ MoPC លើកកម្ពស់សារតាមរយៈទូរស័ព្ទ។

៤) ការផ្តល់អនុសាសន៍ ឫកសរុបលទ្ធផល និងបិទកម្មវិធីដោយឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់លើបទបង្ហាញរបស់ឯកឧត្តមវេជ្ជ. រស់ សីលវ៉ាត់ ដូចតទៅ៖

- ត្រូវប្រើពាក្យ "អ្នកប្រើប្រាស់សេវាកម្មានទេសចរណ៍/EW"។
- Incentive គួរពិភាក្សាជាមួយអង្គការ និងការប្រើប្រាស់កញ្ចប់ថវិកាជាតិការងារអេដស៍ (អាចដកទៅឱ្យ Incentive បានដែរឬទេ?)។
- ឱ្យពិនិត្យដល់អ្នកស្ម័គ្រចិត្តធ្វើតេស្តរកមេរោគអេដស៍ ដើម្បីទទួលបានបណ្ណ ID Poor និងបសស។

ឯកឧត្តម ជា ប៉ោ គួរតែរៀបចំកិច្ចប្រជុំជាមួយតារាសម្តែង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ដែលដឹកនាំដោយឯកឧត្តមប្រធាន។ Website របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវដាក់ទាំងអស់នៅកន្លែងធ្វើតេស្តរកមេរោគអេដស៍ និងព្យាបាលជំងឺអេដស៍។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ចំនួន ១០ចំនុច ៖

១) បន្តការចូលរួមជាមួយមូលនិធិសកល។
២) ចូលរួមក្នុងការរៀបរៀងមូលនិធិសកល និងពិនិត្យមើលខ្លឹមសារ ថាតើវិស័យឯកជន បានបង្កើនការធ្វើតេស្តត្រូវតាមគោលបំណងដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចង់បានដែរឬទេ?
៣) បន្តតាមដានការអនុវត្តគម្រោងរបស់មូលនិធិសកល?
៤) លិខិតចងក្រងគោលនយោបាយបញ្ចប់អេដស៍ នៅឆ្នាំ២០២៥ និងចិរភាពនៃកម្មវិធីអេដស៍ ឆ្នាំ២០២៣-២០២៨។
៥) បានរៀបចំវេទិកាពិគ្រោះយោបល់ទូលំទូលាយ ស្តីពីការរៀបចំគោលនយោបាយបញ្ចប់អេដស៍ ឆ្នាំ២០២៣-២០២៨។
៦) ត្រៀមរៀបចំប្រជុំ GDJ លើកទី១ សម្រាប់ឆ្នាំ២០២៣ ហើយអញ្ជើញ UNAIDS WHO តំណាង KP និងPLHIV។
៧) កំណត់យកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ សម្រាប់រៀបចំកិច្ចប្រជុំពេញអង្គលើកទី១ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ សូមជម្រាបជូន MAC និងPAC ដើម្បីផ្ញើរបាយការណ៍មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
៨) រៀបរៀបចំធ្វើរបាយការណ៍នៃកិច្ចប្រជុំ។

៩) តួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាអ្នកសម្របសម្រួលបញ្ហាអេដស៍។

១០) ត្រូវខិតខំផ្សព្វផ្សាយហានិភ័យនៃជំងឺអេដស៍ឱ្យបានគ្រប់ទីកន្លែងវេទិកា។

ជាទីបញ្ចប់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណ និងសូមជូនពរដល់អ្នកចូលរួមទាំងអស់ និងប្រកាសបិទ។

អង្គប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង១១:៣០នាទីព្រឹកនាថ្ងៃខែឆ្នាំដដែល៕

ថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣

អ្នកធ្វើកំណត់ហេតុ

បានពិនិត្យត្រឹមត្រូវ
អគ្គលេខាធិការ អ.ជ.ប.ជ.អ

វេជ្ជ. ប៉ែន សេរីវង្ស

បណ្ឌិត ឈឹម យិនដារ៉ែត

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ
ទេសរដ្ឋមន្ត្រីប្រធាន អ.ជ.ប.ជ.អ

អៀង មុលី